នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
ចូល លេខ: 1542 របកទ
ម៉ោង 10h25 ថ្ងៃទី 30/6/11
បញ្ជូនទៅ:
អ្នកទទួល:

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៦១៤

## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ដែលសរសេរអក្សរកាត់ថា **គ.ជ.វ.ទ.** ដើម្បីវាយតម្លៃទីក្រុងស្អាត តាមរយៈការប្រឡងប្រណាំង ក្នុងគោលបំណងលើកកម្ពស់សោភ័ណភាព អនាម័យ បរិស្ថានល្អនៅតាមបណ្តាទីក្រុង ពិសេសចូលរួមធ្វើឱ្យទីក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្លាយជាគោលដៅទេសចរណ៍ ដែលទាក់ទាញ និងប្រកបដោយភាពកក់ក្តៅ។

## ជំពូកទី២
## សមាសភាព

**មាត្រា ២.-**

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន | ០១ រូប | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | | សមាជិក |
| - ប្រធានគណៈកម្មការគ្រប់គ្រង អភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្តទាំង២៤ | | សមាជិក |
| - អគ្គលេខាធិការគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងរបស់ **គ.ជ.វ.ទ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

# ជំពូកទី៣

## តួនាទីនិងភារកិច្ចរបស់ គ.ជ.ទ.ឧ.

**មាត្រា ៣.-**

**គ.ជ.ទ.ឧ.** មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- អនុវត្តយុទ្ធនាការអប់រំ និងផ្សព្វផ្សាយជាសាធារណៈ អំពីការប្រឡងប្រណាំងទីក្រុងស្អាត
- កំណត់ទម្រង់ និងបែបបទនៃការចុះឈ្មោះ ក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- រៀបចំនិងដាក់ឲ្យដំណើរការ ការប្រឡងប្រណាំងទីក្រុងស្អាត
- វាយតម្លៃទីក្រុងស្អាត ដោយផ្អែកលើស្តង់ដារទីក្រុងស្អាត ដែលជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ
- ចេញស្លាកសញ្ញាផ្លូវការឲ្យទីក្រុងដែលជាជ័យលាភី
- ពិនិត្យនិងតាមដាន ការអនុវត្តរបស់ទីក្រុងជ័យលាភី ក្រោយទទួលបានស្លាកសញ្ញាពី **គ.ជ.ទ.ឧ.**
- ផ្តល់អនុសាសន៍និងណែនាំដល់ទីក្រុងបេក្ខភាព ដែលពុំទាន់បានឆ្លើយតបនឹងលក្ខណវិនិច្ឆ័យ ក្នុងស្តង់ដារទីក្រុងស្អាត
- ដកហូតស្លាកសញ្ញា ពីទីក្រុងជ័យលាភីទាំងឡាយណា ដែលបាត់បង់ ឬមិនគោរពតាមលក្ខណវិនិច្ឆ័យ នៃស្តង់ដារទីក្រុងស្អាត
- រៀបចំនិងធ្វើបច្ចុប្បន្នភាព លើសូចនាករនិងនីតិវិធី ក្នុងការប្រឡងប្រណាំងទីក្រុងស្អាត
- ធ្វើសហការជាមួយនឹងក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើ ឲ្យកាន់តែមានប្រសិទ្ធភាព
- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

# ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ជ.ទ.ឧ.

**មាត្រា ៤.-**

**គ.ជ.ទ.ឧ.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៥.-**

**គ.ជ.ទ.ឧ.** អាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងក្របខណ្ឌការងាររបស់ខ្លួន។

**មាត្រា ៦._**

បែបបទនិងនីតិវិធីការងាររបស់ **គ.ជ.ទ.ឆ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ទ.ឆ.**។

**មាត្រា ៧._**

**គ.ជ.ទ.ឆ.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួន តាមការចាំបាច់។

**មាត្រា ៨._**

**គ.ជ.ទ.ឆ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលត្រូវមានទីតាំងស្ថិតនៅក្នុងក្រសួងទេសចរណ៍។

**មាត្រា ៩._**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឆ.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ទ.ឆ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ១០._**

**គ.ជ.ទ.ឆ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា ១១._**

**គ.ជ.ទ.ឆ.** មានប្រភពធនធានផ្តល់ផ្គង់ដោយកញ្ចប់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍ និងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ព្រមទាំងប្រភពស្របច្បាប់ផ្សេងទៀតសម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១២._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១៣.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១១

៣៩ល. ១១០៦. ៦២៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខៈ ៥៩៦ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ខិនកេន**